# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤២៣

## ស្តីពី

## ការបង្កើតគណៈវិស្វករកម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩

## ត្រាស់បង្គាប់

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

មាត្រា ១ ..

ត្រូវបានបង្កើតគណៈវិស្វករកម្ពុជា ដែលសរសេរកាត់ថា "គ.វិ.ក." ដើម្បីប្រមូលផ្តុំ និងគ្រប់គ្រងវិស្វករចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ ..

ព្រះរាជក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- រួមចំណែករៀបចំវិជ្ជាជីវៈវិស្វកម្មឱ្យកាន់តែល្អប្រសើរ ដើម្បីការពារកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់វិស្វករ
- រួមចំណែកថែរក្សា និងលើកស្ទួយអត្តសញ្ញាណជាតិ
- ពង្រឹងសមត្ថភាពបច្ចេកទេសគ្រប់ជំនាញ និងពង្រីកធនធានមនុស្សឱ្យស្របតាមកាលៈទេសៈបច្ចុប្បន្ន និងអនាគត
- ធានាឱ្យការប្រកបវិជ្ជាជីវៈវិស្វកម្មមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាព ស្ថិរភាព និងការទទួលខុសត្រូវខ្ពស់
- ពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងផ្ទៃក្នុងវិស្វកម្មថ្នាក់ជាតិ និងទំនាក់ទំនងរវាងវិស្វកម្មជាតិ និងវិស្វកម្មអន្តរជាតិ
- ទទួលស្គាល់គុណភាពរបស់វិស្វករកម្ពុជា ដើម្បីឱ្យមានគោរមងារជាវិស្វករអាជីពជាតិ និងអន្តរជាតិ
- រួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈវិស្វកម្ម ដើម្បីអភិវឌ្ឍធនធានមនុស្សឱ្យស្របតាមតម្រូវការសង្គម ។

មាត្រា ៣ ..

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះវិស្វករខ្មែរ និងវិស្វករបរទេសដែលបានចុះបញ្ជីនៅ គ.វិ.ក. ។ ព្រះរាជក្រឹត្យនេះមិនមានវិសាលភាពអនុវត្តចំពោះវិស្វករ ដែលកំពុងបំពេញការងារក្នុងក្របខណ្ឌក្រសួង និងស្ថាប័នរដ្ឋឡើយ ។

មាត្រា ៤ ..

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះមាននិយមន័យដូចតទៅ ៖

- វិស្វករ សំដៅដល់រូបវន្តបុគ្គលខ្មែរ និងបរទេសដែលបានបញ្ចប់ការសិក្សាជំនាញវិស្វកម្មដោយជោគជ័យនៅតាមគ្រឹះស្ថានឧត្តមសិក្សានានានៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ហើយមានការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា

- វិស្វករអាជីព សំដៅដល់វិស្វករខ្មែរ និងវិស្វករបរទេស ដែលបានចុះឈ្មោះទទួលស្គាល់ក្នុងបញ្ជីនៃ គ.វិ.ក. និងបានបំពេញលក្ខខណ្ឌស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា

- វិស្វករអាស៊ាន សំដៅដល់រូបវន្តបុគ្គលដែលមានសញ្ជាតិ ក្នុងប្រទេសជាសមាជិកអាស៊ាន និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ ស្របតាមកិច្ចព្រមព្រៀងនៃការទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្មវិស្វកម្មរបស់អាស៊ាន ក្រោមការត្រួតពិនិត្យ និងវាយតម្លៃរបស់គណៈកម្មាធិការចុះបញ្ជីវិស្វករអាស៊ាន

- វិជ្ជាជីវៈវិស្វកម្ម សំដៅដល់ការងារពាក់ព័ន្ធនឹងការសិក្សាគម្រោង ការអនុវត្ត និងលិខិតបទដ្ឋានបច្ចេកទេសទាំងឡាយ ដែលទាក់ទងនឹងការងារវិស្វកម្ម ។




## ជំពូកទី២
## ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិស្វករកម្ពុជា
### ផ្នែកទី១
### ប្រធានកិត្តិយសនៃគណៈវិស្វករកម្ពុជា

មាត្រា ៥ ..

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស នៃ គ.ទ.ក. ។

មាត្រា ៦ ..

ប្រធានកិត្តិយស នៃ គ.ទ.ក. ជាអធិបតីក្នុងមហាសន្និបាត គ.ទ.ក. និងផ្តល់អនុសាសន៍ដល់ គ.ទ.ក. ។

## ជំពូកទី២

## មហាសន្និបាត

មាត្រា ៧ ..

- មហាសន្និបាតប្រចាំឆ្នាំ គ.ទ.ក. ត្រូវប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធាន ក្រុមប្រឹក្សា គ.ទ.ក.

- មហាសន្និបាត គ.ទ.ក. ប្រព្រឹត្តទៅ ០៥(ប្រាំ) ឆ្នាំម្តង ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសអគ្គលេខាធិការ និងអគ្គលេខាធិការរង

- មហាសន្និបាតវិសាមញ្ញអាចប្រព្រឹត្តទៅបាន តាមការសម្រេចរបស់ប្រធានក្រុមប្រឹក្សា គ.ទ.ក. ឬតាមការស្នើសុំពីវិស្វករចុះបញ្ជីយ៉ាងតិចចំនួន៣០ (សាមសិប)ភាគរយ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ មុនថ្ងៃប្រជុំ ដោយមានភ្ជាប់របៀបវារៈមកជាមួយផង។

មាត្រា ៨ ..

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មហាសន្និបាត គ.ទ.ក. ដូចមានចែងក្នុងមាត្រា ៧ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង គ.ទ.ក. ។

## ជំពូកទី៣

## ក្រុមប្រឹក្សាគណៈវិស្វករកម្ពុជា

មាត្រា ៩ ..

ក្រុមប្រឹក្សា គ.ទ.ក. មានសមាសភាពដូចតទៅ ÷

| | |
|---|---|
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់នៃស្ថាប័នជាតិដែលមានបទពិសោធខាងវិស័យវិស្វកម្ម | អនុប្រធាន |
| - តំណាងក្រសួងស្ថាប័នដែលពាក់ព័ន្ធនឹងវិស័យវិស្វកម្ម | សមាជិក |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល | សមាជិក |
| - តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |
| - អគ្គលេខាធិការ គ.ទ.ក. | សមាជិកអចិន្ត្រៃយ៍ |

សមាសភាពក្រុមប្រឹក្សា គ.ទ.ក. ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

មាត្រា ១០ ..

ក្រុមប្រឹក្សា គ.ទ.ក. មានសិទ្ធិទាក់ទងនិងអញ្ជើញតំណាងក្រសួង ស្ថាប័ននានាដែលពុំមានចែងក្នុងមាត្រា៩ ខាងលើ ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងតំណាងប្រទេសនានា តាមការចាំបាច់ដើម្បីចូលរួមប្រជុំផ្តល់យោបល់ ឬធ្វើជាអ្នកសង្កេតការណ៍។

**មាត្រា ១១ ..**

ក្រុមប្រឹក្សា គ.វ.ក. មានភារកិច្ចដូចតទៅ ÷

- អនុម័តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌ គ.វ.ក.
- តាមដាននិងត្រួតពិនិត្យដំណើរការការងារ គ.វ.ក.
- ផ្តល់យោបល់ដល់អគ្គលេខាធិការដ្ឋានអំពីការងារចាំបាច់
- សម្របសម្រួលនិងដោះស្រាយរាល់វិវាទផ្សេងៗរបស់ គ.វ.ក.
- ផ្តល់យោបល់ក្នុងការចុះបញ្ជីវិស្វករអាជីព ការលើកទឹកចិត្ត និងការដាក់វិន័យ ។

**មាត្រា ១២ ..**

ក្រុមប្រឹក្សា គ.វ.ក. ត្រូវប្រជុំយ៉ាងតិចរៀងរាល់ ០១ (មួយ)ឆ្នាំម្តង។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំជាវិសាមញ្ញបាន ។

## ជំពូកទី៤

## អគ្គលេខាធិការដ្ឋាន

**មាត្រា ១៣ ..**

គ.វ.ក. មានអគ្គលេខាធិការដ្ឋានមួយ ដែលមានតួនាទីជាអង្គភាពប្រតិបត្តិ និងមានភារកិច្ចដូចតទៅ ÷

- រៀបចំ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌វិស្វករ ដែលអនុម័តដោយក្រុមប្រឹក្សា គ.វ.ក.
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ដំណើរការ គ.វ.ក.
- ធានានិរន្តរភាពការងារនៃអគ្គលេខាធិការដ្ឋាន គ.វ.ក.
- ផ្សព្វផ្សាយអនុសញ្ញា កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងនឹងវិស័យវិស្វកម្មគ្រប់ជំនាញ និងចូលរួមរៀបចំច្បាប់ និងបទដ្ឋានគតិយុត្តទាំងឡាយ តាមការអញ្ជើញរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ
- ជួយសម្រួលក្នុងការការពារកម្មសិទ្ធិបញ្ញារបស់វិស្វករអាជីព
- ពង្រឹងសមត្ថភាពចូលរួមក្នុងការប្រកួតប្រជែងដោយយុត្តិធម៌ និងស្មើភាពគ្នារវាងវិស្វករអាជីពកម្ពុជា និងវិស្វករបរទេស
- ធ្វើសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់កម្មវិធីសិក្សា វគ្គបំប៉នជំនាញ និងការអប់រំក្រោយឧត្តមសិក្សា
- លើកស្ទួយការបណ្តុះបណ្តាលបន្តដល់វិស្វករកម្ពុជា ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈវិស្វកម្មឱ្យមានការទទួលស្គាល់ក្នុងក្របខណ្ឌអាស៊ាន និងអន្តរជាតិ តាមគោលការណ៍នៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកក្នុងអាស៊ាន
- ពិនិត្យតាមដានការប្រកបវិជ្ជាជីវៈវិស្វកម្មរបស់វិស្វករអាជីពកម្ពុជា និងវិស្វករបរទេស
- ចុះបញ្ជីកំណត់គុណវុឌ្ឍិអាជីពវិជ្ជាជីវៈវិស្វកម្មរបស់រូបវន្តបុគ្គលឱ្យទៅជាវិស្វករអាជីព និងធានានិរន្តរភាព

ROYAUME DU CAMBODGE * LE MINISTERE ... PALAIS ROYAL

ការចុះបញ្ជីវិស្វករអាជីព នៅព្រះរាជាណាចក្រកម្ពុជា

- ជ្រើសរើស និងវាយតម្លៃលើបេក្ខភាពវិស្វករអាជីពកម្ពុជា ដើម្បីឱ្យទៅជាវិស្វករអាស៊ាន
- រៀបចំគុណវុឌ្ឍិជំនាញវិជ្ជាជីវៈ និងក្រមសីលធម៌របស់វិស្វករអាជីពដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- ធ្វើកោសល្យវិច័យលើការអនុវត្តការងាររបស់វិស្វករអាជីព ក្នុងករណីមានទំនាស់ក្នុងការបំពេញវិជ្ជាជីវៈ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារ **គ.វិ.ក.** ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ និងក្រុមប្រឹក្សា **គ.វិ.ក.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូន ដោយក្រុមប្រឹក្សា **គ.វិ.ក.** ។

**មាត្រា ១៤ ..**

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ អគ្គលេខាធិការមានឋានៈទាបបំផុតស្មើរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមានឋានៈទាបបំផុតស្មើអនុរដ្ឋលេខាធិការ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន **គ.វិ.ក.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៥ ..**

អគ្គលេខាធិការនិងអគ្គលេខាធិការរង **គ.វិ.ក.** ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ដោយមហាសន្និបាត **គ.វិ.ក.**សម្រាប់អាណត្តិ ០៥ ( ប្រាំ) ឆ្នាំ ។

វិស្វករដែលមានសញ្ជាតិខ្មែរអាចឈរឈ្មោះឱ្យ**គ.វិ.ក.**បោះឆ្នោតជាអគ្គលេខាធិការ ឬអគ្គលេខាធិការរងបានត្រូវមានឈ្មោះក្នុងបញ្ជីវិស្វករអាជីពយ៉ាងតិច ០៥( ប្រាំ) ឆ្នាំ ហើយមិនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬ បទឧក្រិដ្ឋណាមួយឡើយ ។

**មាត្រា ១៦ ..**

ករណីដែលអគ្គលេខាធិការ ឬអគ្គលេខាធិការរងណាម្នាក់ទទួលមរណភាព ឬលាឈប់ពីមុខងារក្នុងអាណត្តិរបស់ខ្លួន **គ.វិ.ក.** ត្រូវជ្រើសរើសអ្នកជំនួសដើម្បីបញ្ចប់អាណត្តិ ស្របតាមបទបញ្ជាផ្ទៃក្នុង ។

**មាត្រា ១៧ ..**

**គ.វិ.ក.** មាននិមិត្តសញ្ញា និងត្រាដោយឡែករបស់ខ្លួន ។

## ផ្នែកទី៥

## ក្រុមប្រឹក្សាគណៈវិស្វកររាជធានី ខេត្ត

**មាត្រា ១៨ ..**

**គ.វិ.ក.**អាចបង្កើតក្រុមប្រឹក្សាគណៈវិស្វកររាជធានី ខេត្តបាន ក្នុងករណីដែលមានសមាជិកជាវិស្វករចុះបញ្ជី ចាប់ពី ២០ (ម្ភៃ) រូបឡើងទៅ ដែលក្នុងនោះត្រូវមានវិស្វករអាជីពយ៉ាងតិច ០៥( ប្រាំ) រូប ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាគណៈវិស្វកររាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គ.ទិ.ភ. ។

## ជំពូកទី៣
## ការប្រកបវិជ្ជាជីវៈវិស្វកម្ម

**មាត្រា ១៩ ..**

វិស្វករ ដែលអាចក្លាយទៅជាវិស្វករអាជីពបាន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

- បានចុះបញ្ជី គ.ទិ.ភ.
- គ្មានការហាមឃាត់ការប្រកបវិជ្ជាជីវៈនេះដោយតុលាការ និង
- បំពេញលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គ.ទិ.ភ. ។

**មាត្រា ២០ ..**

វិស្វករអាជីពអាចប្រកបវិជ្ជាជីវៈវិស្វកម្មដោយខ្លួនឯងបាន ដោយត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

វិស្វករអាចប្រកបវិជ្ជាជីវៈវិស្វកម្មបានដោយមានការទទួលខុសត្រូវរបស់វិស្វករអាជីព ។

**មាត្រា ២១ ..**

វិស្វករដែលបានបំពេញគ្រប់លក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១៩ ខាងលើត្រូវទទួលបានវិញ្ញាបនបត្រវិស្វករអាជីព ដែលចេញ ដោយ គ.ទិ.ភ. ។

**មាត្រា ២២ ..**

ជនបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅ គ.ទិ.ភ. និងត្រូវគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៣ ..**

ការប្រកបវិជ្ជាជីវៈវិស្វកម្ម ត្រូវគោរពតាមក្រមសីលធម៌វិស្វករ ដែលអនុម័តដោយក្រុមប្រឹក្សា គ.ទិ.ភ. ។

**មាត្រា ២៤ ..**

វិស្វករខ្មែរនិងវិស្វករបរទេស ដែលបានចុះបញ្ជី គ.ទិ.ភ.នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបង់ភាគទានប្រចាំឆ្នាំជូន គ.ទិ.ភ. ។

ភាគទានដែលត្រូវបង់ជូន គ.ទិ.ភ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គ.ទិ.ភ. ។

ROYAUME DU CAMBODGE * LE MINISTERE ... ROYAL *

មាត្រា ២៥

វិស្វករចុះបញ្ជី និងវិស្វករអាជីព អាចសុំព្យួរការប្រកបវិជ្ជាជីវៈរបស់ខ្លួនបាន តាមការកំណត់របស់ **គ.វិ.ក.** ។

## ជំពូកទី៤

## គោរម្យងារកិត្តិយស

**មាត្រា ២៦ ..**

**គ.វិ.ក.** អាចផ្ដល់គោរម្យងារជាវិស្វករកិត្តិយសជូនដល់វិស្វករអាជីព ក្រោយពីបានប្រកបវិជ្ជាជីវៈវិស្វកម្ម រយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំឡើងទៅ ។

**គ.វិ.ក.** អាចផ្ដល់គោរម្យងារជាសមាជិកកិត្តិយសជូនដល់ឥស្សរជន ឬបុគ្គលទាំងឡាយណា ដែលបានឧបត្ថម្ភគាំទ្រផ្នែកថវិកា ឬ បច្ចេកទេសដល់ **គ.វិ.ក.** តាមការកំណត់របស់ក្រុមប្រឹក្សា **គ.វិ.ក.** ។

**មាត្រា ២៧ ..**

គោរម្យងារជាវិស្វករកិត្តិយសអាចត្រូវដកវិញបាន ប្រសិនបើវិស្វកររូបនោះបានប្រព្រឹត្តផ្ទុយនឹងវិធានបច្ចេកទេស ឬក្រមសីលធម៌វិស្វករ ទោះបីការប្រព្រឹត្តនោះ នៅក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។

## ជំពូកទី៥

## ក្រុមប្រឹក្សាវិន័យ

**មាត្រា ២៨ ..**

ក្រុមប្រឹក្សាវិន័យមានសមាសភាពចំនួន ០៥ (ប្រាំ)រូប ដែលត្រូវតែងតាំងឡើងដោយប្រធានក្រុមប្រឹក្សា **គ.វិ.ក.** ក្នុងចំណោមសមាជិកក្រុមប្រឹក្សា **គ.វិ.ក.** និងសមាជិកនៃអគ្គលេខាធិការដ្ឋាន **គ.វិ.ក.** ។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការសម្រេចដាក់វិន័យ ត្រូវកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុង **គ.វិ.ក.** ។

**មាត្រា ២៩ ..**

ក្រុមប្រឹក្សាវិន័យមានតួនាទីដូចតទៅ ÷

- ទទួលបណ្ដឹងតវ៉ាផ្សេងៗពាក់ព័ន្ធនឹងវិស្វករដែលបានចុះបញ្ជីនៅ **គ.វិ.ក.**
- ដោះស្រាយវិវាទទាក់ទងនឹងវិជ្ជាជីវៈវិស្វករដែលបានចុះបញ្ជីនៅ **គ.វិ.ក.**
- ដាក់ទណ្ឌកម្មខាងវិន័យដល់វិស្វករណាដែលប្រព្រឹត្តផ្ទុយនឹងវិធានបច្ចេកទេស ឬក្រមសីលធម៌វិស្វករ ។

**មាត្រា ៣០ ..**

វិស្វករដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចដាក់ទណ្ឌកម្មរបស់ក្រុមប្រឹក្សាវិន័យ មានសិទ្ធិប្ដឹងតវ៉ា ទៅប្រធាន ក្រុមប្រឹក្សា **គ.វិ.ក.** ។ ប្រធានក្រុមប្រឹក្សា **គ.វិ.ក.** ត្រូវចាត់តាំងសមាជិកចំនួន ០៧ (ប្រាំពីរ) រូបផ្សេងទៀត ក្រៅពីសមាសភាពក្រុមប្រឹក្សាវិន័យ ដើម្បីពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ានោះ ។ សេចក្ដីសម្រេចចុងក្រោយនេះ ជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ។

ROYAUME DU CAMBODGE * JOURNAL OFFICIEL

បែបបទ និងនីតិវិធីនៃការតវ៉ា និងរយៈពេលនៃការធ្វើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាវិន័យ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង គ.ទ.គ. ។

## ជំពូកទី៦

## ទណ្ឌកម្មខាងវិន័យ

**មាត្រា ៣១ ..**

ទណ្ឌកម្មខាងវិន័យរួមមាន ÷

- ការព្រមាន
- ការស្តីបន្ទោស
- ការព្យួរសិទ្ធិមួយរយៈពេលដែលពុំអាចលើសពី ០២ (ពីរ) ឆ្នាំ
- ការលុបឈ្មោះចេញពីបញ្ជី គ.ទ.គ. ឬហូតគោរម្យងារកិត្តិយស ។

ការទទួលទណ្ឌកម្មខាងវិន័យ មិននាំឱ្យបុគ្គលនោះរួចផុតពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌឡើយ ។

## ជំពូកទី៧

## ប្រភពធនធាន

**មាត្រា ៣២ ..**

ប្រភពធនធានរបស់ គ.ទ.គ. សម្រាប់បំពេញការងាររបស់ខ្លួនបានមកពី ÷

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ភាគទានដែលបានពីសមាជិក គ.ទ.គ.
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយកតសំណងផ្សេងៗ ។

គ.ទ.គ. មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀតពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៨

## អន្តរប្បញ្ញត្តិ

**មាត្រា ៣៣ ..**

ក្នុងអាណត្តិដំបូង អគ្គលេខាធិការ និងអគ្គលេខាធិការរងនៃ គ.ទ.គ. ត្រូវតែងតាំងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ប្រធានក្រុមប្រឹក្សា គ.ទ.គ. ។

ROYAUME DU CAMBODGE * LE MINISTRE ... ROYAL *

**មាត្រា ៣៤ ..**

វិស្វករទាំងឡាយដែលបាន និងកំពុង ឬមានបំណងប្រកបវិជ្ជាជីវៈវិស្វកម្ម ត្រូវមកសុំបំពេញបែបបទ និងចុះឈ្មោះក្នុងបញ្ជី គ.វ.ក. ស្របតាមលក្ខខណ្ឌដែលបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា ៣៥ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣៦ ..**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៤០៥.១២៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ៣៧៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៥

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**